ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍ប្រចាំខែមេសា ឆ្នាំ២០១៦

រៀបចំដោយអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ

# ១. សេចក្តីផ្តើម

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ (អ.ជ.ប.ជ.អ) ជាស្ថាប័នជាតិតែមួយគត់ដែលមានតួនាទីដឹកនាំគ្រប់គ្រង សម្របសម្រួល និងតាមដានការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមរយៈការឆ្លើយតបទូលំទូលាយ និងពហុវិស័យ។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដឹកនាំ និងសម្របសម្រួលការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍តាមរយៈការផលិត និងអនុវត្តនូវផែនការយុទ្ធសាស្រ្តជាតិឆ្លើយតបទូលំទូលាយ និងពហុវិស័យមួយ យោ ងតាមការអនុវត្តគោលការណ៍បី-មួយ និងក្នុងគោលបំណងធ្វើឲ្យសម្រេចនូវគោលដៅអភិវឌ្ឍន៍ របស់រាជរដ្ឋាភិបាលកម្ពុជា និងគោលដៅជាយុទ្ធសាស្រ្តបី-សូន្យ ឆ្នាំ២០២០ (មិនមានការ ឆ្លងមេរោគអេដស៍ថ្មី មិនមានការស្លាប់ដោយសារជំងឺអេដស៍ មិនមានការរើសអើង និងមាក់ងាយដល់អ្នកផ្ទុកមេរោគអេដស៍) ព្រមទាំងគោលដៅ ៩០/៩០/៩០ នៃអង្គការ ( UNAIDS) គឺ ៩០%នៃអ្នកផ្ទុកមេរោគអេដស៍បានធ្វើតេស្តឈាម៩០% នៃអ្នកមានតេស្តឈាមវិជ្ជមានបានទទួលការព្យាបាល និង ៩០% នៃអ្នកបានទទួលការព្យាបាលមានវិរុសឲ្យនៅក្រោមកម្រិតមើលឃើញ។ ដើម្បីតាមដានការអនុវត្តភារកិច្ចនេះ អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ ជាសេនាធិការ មានតួនាទីរៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំជាពហុវិស័យស្តីអំពីសកម្មភាព វឌ្ឍនភាព និងសមិទ្ធផលដែលទទួលបានពីការអនុវត្តសកម្មភាពការងាររបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ និងអគ្គលេខាធិការដ្ឋាន ព្រមទាំងមន្ត្រីនៃនាយកដ្ឋានទាំងអស់ និងស្ថាប័នពាក់ព័ន្ធ។

របាយការណ៍ប្រចាំខែមេសា ឆ្នាំ២០១៦នេះរួមបញ្ចូលនូវវឌ្ឍនភាព និងសមិទ្ធផលនៃការអនុវត្តផែនការសកម្មភាពរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន និងមន្ត្រីដូចខាងក្រោមៈ

- សកម្មភាព និងសមិទ្ធផលសម្រេចបានដោយថ្នាក់ដឹកនាំ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- សកម្មភាព និងសមិទ្ធផលសម្រេចបានដោយអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- សកម្មភាព និងសមិទ្ធផលសម្រេចបានដោយនាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ។
- សកម្មភាព និងសមិទ្ធផលសម្រេចបានដោយនាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន។

- សកម្មភាព និងសមិទ្ធផលសម្រេចបានដោយនាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ។
- សកម្មភាព និងសមិទ្ធផលសម្រេចបានដោយនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ។
- ទិសដៅការងារសម្រាប់ខែបន្ទាប់របស់នាយកដ្ឋាននីមួយៗ ។

# ២. សកម្មភាព និងសមិទ្ធផល

## ២.១. សកម្មភាព និងសមិទ្ធផលដែលសម្រេចបានដោយថ្នាក់ដឹកនាំ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

នៅខែមេសានេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ រួមជាមួយនឹងថ្នាក់ដឹកនាំទាំងអស់បានដឹកនាំធ្វើសកម្មភាពការងារ និងសម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

នៅព្រឹកថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** បានអញ្ជើញចូលរួមក្នុងពិធីថ្វាយព្រះពរជូនព្រះករុណា **ព្រះបាទនរោត្តម សីហមុនី**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា រៀបចំដោយសហភាពសហព័ន្ធយុវជនកម្ពុជារៀបចំដោយ **ឯកឧត្តម ហ៊ុន មានី។**

នៅព្រឹកថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០១៧ ។

នៅព្រឹកថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ **ឯកឧត្តម អៀង មូលី** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានអញ្ជើញចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីក្រោមការដឹកនាំអង្គប្រជុំរបស់ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅវិមានសន្តិភាពរាជធានីភ្នំពេញ។

របៀបវារៈនៃអង្គប្រជុំនាសប្តាហ៍នេះរួមមានៈ

១. សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

២. សេចក្តីព្រាងផែនការមេឆ្ពោះទៅការធ្វើជាម្ចាស់ផ្ទះការប្រកួតកីឡាអាស៊ីអាគ្នេយ៍ (SEA Games) លើកទី៣២ ឆ្នាំ២០២៣ (២០១៦-២០២៣)។

៣. បញ្ហាផ្សេងៗ: សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ន នីតិប្បញ្ញត្តិលើ «កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល ហុង គ្រី ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ»។

**ឯកឧត្តម អៀង មូលី** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក៏បានអញ្ជើញចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនោះផងដែរ ។ បន្ទាប់ពីការពិភាក្សាផ្លាស់ប្តូរយោបល់យ៉ាងយូរគណៈរដ្ឋមន្ត្រីបានពិនិត្យអនុម័តលើ សេចក្តីព្រាងច្បាប់ សេចក្តីព្រាងផែនការមេ និង ឯកសារខាងលើ។ អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង ១១ និង ៣០នាទី។

នាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី**បានអញ្ជើញចូលរួមពិធីសម្ពោធផ្លូវលេខ៥៦ពីខេត្តបន្ទាយមានជ័យទៅខេត្តឧត្តរមានជ័យ ប្រវែង១២៤ គីឡូម៉ែត នៅវិទ្យាល័យថ្មរពួកក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

នាព្រឹកថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី**បានចូលរួមពិធីចែកសញ្ញាបត្រនិស្សិតសាកលវិទ្យាល័យធនធានមនុស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

## ២.២. សកម្មភាព និងសមិទ្ធផលសម្រេចបានដោយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន

១. នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ឯកឧត្តមអគ្គលេខាធិការ បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សា បច្ចេកទេសលើកទី១ ឆ្នាំ២០១៦ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

២. នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦ ឯកឧត្តមអគ្គលេខាធិការ បានចូលរួមកិច្ចប្រជុំរៀបចំពិធីខួបទី១៥៣ទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ឧសភា ឆ្នាំ២០១៦ នៅកាកបាទក្រហមកម្ពុជា។

៣. នៅថ្ងៃទី២១ ដល់ទី២២ ខែមេសា ឆ្នាំ២០១៦ ឯកឧត្តមអគ្គលេខាធិការ បានចុះទៅពិនិត្យស្ថានភាពអេដស៍ និងការផ្តល់សេវាដល់ក្រុមប្រឈម និងអ្នករស់នៅជាមួយមេរោគអេដស៍នៅខេត្តសៀមរាប ។

## ២.៣. សកម្មភាព និងសមិទ្ធផលសម្រេចបានដោយថ្នាក់ដឹកនាំអគ្គលេខាធិការរង

### សកម្មភាពលោកវេជ្ជ.រស់ សីលវ៉ាត់ ក្នុងខែមេសា ឆ្នាំ២០១៦

១. ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ចូលរួមប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ ពិនិត្យដំណើរការអនុវត្តការងារ។

២. ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ចូលរួមប្រជុំគណៈកម្មការគ្រប់គ្រងជំនួយពិនិត្យវឌ្ឍនភាព និងឧបសគ្គផ្សេងៗក្នុងការអនុវត្តគម្រោងមូលនិធិសកល។
៣. ថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៦ ចូលរួមប្រជុំ បុគ្គលិកអគ្គលេខាធិការដ្ឋាន សិក្សាលើប្រកាសស្តីពីការពង្រឹងវិន័យការងាររបស់យើង។
៤. ទីថ្ងៃ៧ ខែមេសា ឆ្នាំ២០១៦ចូលរួមពិធីសូត្រមន្តចូលឆ្នាំថ្មី នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រោមអធិបតីភាពឯកឧត្តមទេសរដ្ឋមន្ត្រីប្រធាន។
៥. ថ្ងៃទី៧ និង ទី៨ ខែមេសា ឆ្នាំ២០១៦ ពិភាក្សាការងារជាមួយប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ និងប្រធាននាយកដ្ឋាន CRM ពិនិត្យមើល និងបែងចែកភារកិច្ចនាយកដ្ឋានជំនាញនីមួយៗ ទទួលកែលម្អឯកសារផែនការយុទ្ធសាស្ត្រជាតិលើកទី៤ភាសារខ្មែរ។ លោកវេជ្ជ. រស់ សីលវ៉ាត់ និងប្រធាននាយកដ្ឋានជំនាញនីមួយៗ ចាប់យកផ្នែកផ្សេងៗគ្នានៃឯកសារទៅបន្តធ្វើកែលម្អរៀងៗខ្លួន ហើយគ្រោងនឹងប្រមូលមកវិញនៅសប្តាស៍ទី១រឺទី២ ខែឧសភា ឆ្នាំ២០១៦។
៦. ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ ចូលរួមប្រជុំពិភាក្សាការកសាងផែនការយុទ្ធសាស្ត្រថវិកាជាតិឆ្នាំ២០១៧ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
៧. ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ចូលរួមប្រជុំរួមប្រចាំខែមេសា ឆ្នាំ២០១៦ អំពីការតាមដាន និងផ្តល់ការតម្រង់ទិសការងាររដ្ឋបាលមួយចំនួន។
៨. ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ជួបជាមួយអ្នកប្រឹក្សារបស់អង្គការយូអេសអាយឌី (USAID) ផ្តល់ព័ត៌មានពាក់ព័ន្ធនឹងស្ថានភាពរីករាលដាលមេរោគអេដស៍ ស្ថានភាពអន្តរាគមន៍ ស្ថានភាពមូលនិធិហិរញ្ញប្បទានក្នុងការប្រយុទ្ធនឹងមេរោគ អេដស៍/ជំងឺអេដស៍ កិច្ចសហប្រតិបត្តិការក្នុងតំបន់ និងយុទ្ធសាស្ត្រភាពជាដៃគូរាជរដ្ឋាភិបាល និងវិស័យឯកជន ដើម្បីឆ្លើយតបនឹងមេរោគអេដស៍ក្នុងចំណោមប្រជាជនចល័តក្នុង និងក្រៅប្រទេស ព្រមទាំងយុទ្ធសាស្ត្រថវិកាឆ្ពោះទៅរកនិរន្តរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍/ជំងឺអេដស៍។
៩. ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ចូលរួមប្រជុំពិនិត្យបន្តការកសាងផែនការយុទ្ធសាស្ត្រថវិកាជាតិឆ្នាំ២០១៧ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
១០.ពិនិត្យឯកសារនិយាមប្រតិបត្តិបែបបទអនុវត្តស្តីពីដៃគូសហគមន៍ ដើម្បីប្រជាជនប្រឈម មុខខ្ពស់ (MCPI-SOP) ដាក់ជូនដោយលោកវេជ្ជ.ទា ផូលី ជាទីប្រឹក្សា បច្ចេកទេសរយៈពេលខ្លី ដោយគ្រោងនឹងជួបជាមួយក្រុម

ការងារ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ ២០១៦ ដើម្បីសំយោគយោបល់ ផ្តល់ត្រឡប់ទៅទីប្រឹក្សាបច្ចេកទេសវិញ មុននឹងរៀបចំកិច្ចប្រជុំពិនិត្យចុងក្រោយ។

## ២.៤. សកម្មភាព និងសមិទ្ធផលសម្រេចបានដោយនាយកដ្ឋានផែនការ គ្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ (PMER)

នៅក្នុងខែមេសា ឆ្នាំ២០១៦នេះ នាយកដ្ឋានផែនការ គ្រួតពិនិត្យ វាយតំលៃ និង ស្រាវជ្រាវ (PMER) បានអនុវត្ត និងសម្រេចបានការងារមួយចំនួនដូចខាងក្រោម៖

**សកម្មភាពបានអនុវត្ត និងសកម្មភាពសម្រេចបាន ៖**

១. នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ បន្តប្រជុំពិភាក្សាការងារជាមួយមន្ត្រី UNAIDS និង Consultant ស្តីពី NASA និង GARPR។

២. នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ បានចូលរួមកិច្ចប្រជុំរួមរបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣. នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ មន្ត្រីនាយកដ្ឋានបានចូលរួមកិច្ចប្រជុំស្តីពីការរៀបចំបណ្ណាល័យរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការចូលរួមពីបណ្តាស្ថាប័នដូចជា NGO IHF360 RKAC និងស្ថាប័នផ្សេងទៀតក្នុងគោលបំណងផ្តល់ព័ត៌មានអំពី មេរោគអេដស៍/ជំងឺអេដស៍។

៤. នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ មន្ត្រីនាយកដ្ឋានបានចូលរួមប្រជុំជាមួយថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ស្តីពីគោលការណ៍ផែនការសកម្មភាពប្រើប្រាស់ថវិកាជាតិសម្រាប់ឆ្នាំ២០១៧ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៥. នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ប្រធាននាយកដ្ឋានបានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយ អំពីការសិក្សាតម្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍន៍តំបន់អាស៊ីប៉ាស៊ីហ្វិក (UN-ESCAP) រៀបចំដោយគណៈកម្មាធិការជាតិ ESCAP ។

៦. នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៦ ប្រធាននាយកដ្ឋានបានចូលរួមសិក្ខាសាលាស្តីពី ការដាក់បញ្ចូល SDG ក្នុងផែនការអភិវឌ្ឍន៍ជាតិ ឆ្នាំ២០៣០ រៀបចំដោយគណៈកម្មាធិការជាតិ ESCAP និងក្រសួងផែនការ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។

៧. នាយកដ្ឋានបានត្រៀមរៀបចំកិច្ចប្រជុំផ្សព្វផ្សាយជាផ្លូវការ ស្តីពីការអង្កេតជាតិ ការចំណាយក្នុងការប្រយុទ្ធនឹងជំងឺអេដស៍សម្រាប់ឆ្នាំ ២០១៤-២០១៥

នៅថ្ងៃទី៤-៥ ខែឧសភា ឆ្នាំ២០១៦ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ ហើយបានរៀបចំឯកសារដែលពាក់ព័ន្ធនឹងកិច្ចប្រជុំនេះ និងបាន ធ្វើលិខិតអញ្ជើញ ដើម្បីផ្ញើជូនក្រសួង ស្ថាប័ន ដែលត្រូវចូលរួមក្នុងកិច្ចប្រជុំរួចរាល់។

៨. បានរៀបចំបញ្ជីវត្តមាន និងផ្ញើសារពីការអញ្ជើញចូលរួមកិច្ចប្រជុំផ្សព្វផ្សាយជាផ្លូវការ ស្តីពីការអង្កេតជាតិ ការចំណាយក្នុងការប្រយុទ្ធនឹងជំងឺអេដស៍សម្រាប់ឆ្នាំ២០១៤-២០១៥ នៅថ្ងៃទី៤ដល់ ទី៥ ខែឧសភា ឆ្នាំ២០១៦ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ ជូនទៅ ក្រសួង និងស្ថាប័នពាក់ព័ន្ធ។

៩. បានបញ្ចប់ការងារធ្វើការប្រមូលរបាយការណ៍វឌ្ឍនភាព ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ផ្ញើជូនអង្គការសហប្រជាជាតិ (GARPR) ២០១៥។

១០. បានបន្តការងារកែសម្រួលឡើងវិញ សៀវភៅយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍លើកទី៤ ឆ្នាំ២០១៥ ដល់ ឆ្នាំ ២០២០។

១១. បានកែសម្រួល និងបញ្ចប់របាយការណ៍កិច្ចប្រជុំអន្តរក្រសួងស្តីពី គម្រោងផែនការសកម្មភាពឆ្លើយតមមេរោគអេដស៍ និងជំងឺអេដស៍ដោយប្រើប្រាស់ថវិកាជាតិសម្រាប់ឆ្នាំ២០១៧ ហើយដាក់ជូនថ្នាក់ដឹកនាំ ពិនិត្យ និងសម្រេច។

១២. បានបញ្ចប់របាយការណ៍សកម្មភាពការងារប្រចាំខែមីនា ឆ្នាំ២០១៦ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងដាក់ជូនថ្នាក់ដឹកនាំ ពិនិត្យ និងសម្រេច។

១៣. បានបន្តធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែមេសាឆ្នាំ២០១៦ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

១៤. បានធ្វើរបាយការណ៍សកម្មភាពបានអនុវត្តប្រចាំសប្តាហ៍ទី១ ដល់ ទី៤ ខែមេសា ឆ្នាំ២១០៦ របស់នាយកដ្ឋាន PMER ។

## ២.៥. សកម្មភាព និងសមិទ្ធផលសម្រេចបានដោយនាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

នៅក្នុង ខែមេសា ឆ្នាំ២០១៦ នេះ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន បានអនុវត្ត និងសម្រេចនូវលទ្ធផលមួយចំនួនដូចខាងក្រោម៖

**ក. សកម្មភាពបានអនុវត្តៈ**

១. បានប្រជុំស្វែងយល់អំពី លំហូរថវិកាសម្រាប់ថ្នាក់ក្រោមជាតិទាក់ទងនឹងថវិកា សម្រាប់អ្នកផ្តល់សេវាសុខាភិបាលនៅថ្នាក់សហគមន៍ នៅក្រសួងសុខាភិបាល ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦។

២. ព្រឹកថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ ចូលរួមប្រជុំគណៈកម្មាធិការថវិកា ស្តីពីការលើកគម្រោងថវិកាជាតិសម្រាប់ឆ្នាំ២០១៧។

៣. ល្ងាចថ្ងៃទី ២១ ខែមេសា ឆ្នាំ២០១៦ ប្រជុំថវិកាមូលនិធិសកលស្តីពីការបែងចែកថវិកាបន្ថែមជំនួយផ្នែកច្បាប់ (Legal Barrier) ជាមួយដៃគូអភិវឌ្ឍ។

៤. កែសម្រួលផែនការយុទ្ធសាស្រ្តជាតិលើកទី៤ពីទំព័រ៨៨ ដល់ ទំព័រ១៩៦។

៥. ពិនិត្យលើផែនការមូលនិធិសកលដែលមានលេខខ្ទង់ថវិកា១៥៤ ២០០ និង ២០២។

៦. គម្រោងថវិកាមូលនិធិសកលបន្ថែមចំនួន ២០ ម៉ឺនដុល្លារអាមេរិក សម្រាប់ Legal barrier បានកែសម្រួលកាត់បន្ថយមកត្រឹមចំនួនប្រមាណ ១០ ម៉ឺនដុល្លារអាមេរិកវិញ។

៧. ប្រជុំគណៈកម្មាធិការថវិកាពិភាក្សាពី ការបង្កើតសូចនាករសម្រាប់គម្រោងថវិកាជាតិសម្រាប់ឆ្នាំ២០១៧ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ។

៨. ល្ងាចថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ចូលរួមប្រជុំគណៈកម្មធិការគ្រប់គ្រងមូលនិធិសកលស្តីពី ការពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំ-សង្កាត់លើការផ្តល់សេវាសាធាណៈនៅសហគមន៍ជាពិសេសឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង។

៩. សរសេរខ្លឹមសារសម្រាប់ដាក់ក្នុង វេបសាយ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ធ្វើសេចក្តីព្រៀងការពន្យល់នីតិវិធី និងយន្តការនៃសកម្មភាពកំណាត់អត្តសញ្ញាណភាពក្រីក្រ។

១០. បន្តកែសម្រួលអក្ខរាវិរុទ្ធផែនការយុទ្ធសាស្រ្តជាតិលើកទី៤ ។

១១. ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ប្រជុំគណៈកម្មាធិការថវិកាពិភាក្សាពីការកែសម្រួលសូចនាករ និងខ្លឹមសារលម្អិតលើគម្រោងថវិកាជាតិសម្រាប់ឆ្នាំ២០១៧ បន្ទាប់ពីឆ្លងជាមួយក្រសួងសុខាភិបាល។

១២. ផ្តល់មតិយោបល់កែសម្រួលលើឯកសារ MCPI-SoP ។

## ខ. សកម្មភាពសម្រេចបានៈ

១. បានប្រជុំស្វែងយល់អំពី លំហូរថវិកាសម្រាប់ថ្នាក់ក្រោមជាតិទាក់ទងនឹង ថវិកា សម្រាប់អ្នកផ្តល់សេវាសុខាភិបាលនៅថ្នាក់សហគមន៍ នៅក្រសួងសុខាភិបាល ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦។

២. ព្រឹកថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ ចូលរួមប្រជុំគណៈកម្មាធិការថវិកា ស្តីពីការលើកគម្រោងថវិកាជាតិសម្រាប់ឆ្នាំ២០១៧។

៣. ល្ងាចថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ ប្រជុំថវិកាមូលនិធិសកលស្តីពីការបែងចែកថវិកាបន្ថែមជំនួយផ្នែកច្បាប់ (Legal Barrier) ជាមួយដៃគូអភិវឌ្ឍ។

៤. បានធ្វើការ កែសម្រួលផែនការយុទ្ធសាស្ត្រជាតិលើកទី៤ ពីទំព័រ ៨៨ ដល់ទំព័រ ១៩៦។

៥. ពិនិត្យលើផែនការមូលនិធិសកលដែលមានលេខខ្ទង់ថវិកា១៥៤ ២០០ និង ២០២។

៦. គម្រោងថវិកាមូលនិធិសកលបន្ថែមចំនួន ២០ ម៉ឺនដុល្លារអាមេរិក សម្រាប់ Legal barrier បានកែសម្រួលកាត់បន្ថយមកត្រឹមចំនួនប្រមាណ ១០ ម៉ឺនដុល្លារអាមេរិកវិញ។

៧. ប្រជុំគណៈកម្មាធិការថវិកាពិភាក្សាពី ការបង្កើតសូចនាករសម្រាប់គម្រោងថវិកាជាតិសម្រាប់ឆ្នាំ២០១៧ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ។

៨. ល្ងាចថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ចូលរួមប្រជុំគណៈកម្មធិការគ្រប់គ្រងមូលនិធិសកលស្តីពី ការពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំ-សង្កាត់លើការផ្តល់សេវាសាធារណៈនៅសហគមន៍ជាពិសេសឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង។

៩. សរសេរខ្លឹមសារសម្រាប់ដាក់ក្នុង វេបសាយ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ធ្វើសេចក្តីព្រាងការពន្យល់នីតិវិធី និងយន្តការនៃសកម្មភាពកំណត់អត្តសញ្ញាណភាពក្រីក្រ។

១០. បន្តកែសម្រួលអក្ខរាវិរុទ្ធផែនការយុទ្ធសាស្ត្រជាតិលើកទី៤ ។

១១. ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ប្រជុំគណៈកម្មាធិការថវិកាពិភាក្សាពីការកែសម្រួលសូចនាករ និងខ្លឹមសារលម្អិតលើគម្រោងថវិកាជាតិសម្រាប់ឆ្នាំ ២០១៧ បន្ទាប់ពីឆ្លងជាមួយក្រសួងសុខាភិបាល។

១២. ផ្តល់មតិយោបល់កែសម្រួលលើឯកសារ MCPI-SoP ។

## ២.៦. សកម្មភាព និងសមិទ្ធផលសម្រេចបានដោយនាយកដ្ឋាន បង្ការ ថែទាំ និងគាំទ្រ

នៅក្នុងខែមេសា ឆ្នាំ២០១៦នេះ នាយកដ្ឋាន បង្ការ ថែទាំ និងគាំទ្រ បានអនុវត្ត និងសម្រេចនូវលទ្ធផលមួយចំនួនដូចខាងក្រោម៖

**សកម្មភាពបានអនុវត្ត និងសកម្មភាពសម្រេចបាន ៖**

១. នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦ បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយអនុក្រឹត្យស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា ទៅដល់មន្ត្រីក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

២. នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦ បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការទទួលបន្ទុកការព្យាបាល និងស្តារនិតិសម្បទា អ្នកញៀនគ្រឿងញៀន នៅក្រសួងសុខាភិបាល។

៣. នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ បានចូលរួមកិច្ចប្រជុំ ដើម្បីពិនិត្យមើលផែនការសកម្មភាព និងបញ្ហាប្រឈមក្នុងការប្រើប្រាស់ថវិកាជាតិ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៤. នៅថ្ងៃទី២១ ដល់ ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ អមដំណើរឯកឧត្តមអគ្គលេខាធិការ ចុះអភិបាលកិច្ចការងារអេដស៍ នៅខេត្តកំពង់ចាម ដោយជួបប្រជុំជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ម្ចាស់សេវា អង្គការដៃគូ និងក្រុមគោលដៅ។ ជាមួយគ្នានោះក៏បានចុះពិនិត្យមើលស្ថានភាពអ្នកផ្ទុកមេរោគអេដស៍ អ្នកជំងឺអេដស៍នៅមន្ទីរពេទ្យខេត្ត នៅមន្ទីរពេទ្យបង្អែកស្រុកជើងព្រៃ និងចុះពិនិត្យមើលស្ថានភាពរស់នៅរបស់កម្មករ កម្មការនី នៅរោងចក្រផលិតស្បែកជើង នៃស្រុកជើងព្រៃ ខេត្តកំពង់ចាម។

៥. បានរៀបចំធ្វើរបាយការណ៍ កិច្ចប្រជុំប្រចាំត្រីមាសក្រុមការងារបច្ចេកទេសបុរសស្រឡាញ់បុរស និងស្រីស្រស់ថ្នាក់ក្រោមជាតិ និងពង្រាងឯកសារសម្រាប់រៀបចំកិច្ចប្រជុំក្រុមការងារលេខាធិការដ្ឋាន បុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។

៦. បានចូលរួមរៀបចំឯកសារជ្រើសរើសមន្ត្រីជំនួយការបច្ចេកទេស ដើម្បី ធ្វើការសិក្សាស្តីពីនិយាមប្រតិបត្តិនៃការផ្តួចផ្តើមភាពជាដៃគូរវាងក្រុមប្រឈមមុខខ្ពស់នឹងមេរោគអេដស៍/ជំងឺអេដស៍ និងដៃគូសហគមន៍(MCPI-SOP) ។

៧. បានរៀបចំធ្វើរបាយការណ៍ កិច្ចប្រជុំប្រចាំត្រីមាសក្រុមការងារបច្ចេកទេសបុរសស្រឡាញ់បុរស និងស្រីស្រស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

៨. បានចូលរួមរៀបចំឯកសារជ្រើសរើសមន្ត្រីជំនួយការបច្ចេកទេស ដើម្បីរៀបចំនិយាមប្រតិបត្តិនៃការផ្តួចផ្តើមភាពជាដៃគូរវាងក្រុមប្រឈមមុខខ្ពស់នឹងមេរោគអេដស៍/ជំងឺអេដស៍ និងសហគមន៍ (Baseline Survey MCPI SOP) ។

៩. ចូលរួមប្រជុំបច្ចេកទេសប្រចាំសប្តាហ៍និងប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

១០. បានចូលរួមកិច្ចប្រជុំ ដើម្បីរៀបចំផែនការថវិកាជាតិនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

## ២.៧. សកម្មភាព និងសមិទ្ធផលសម្រេចបានដោយនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

នៅក្នុងខែមេសា ឆ្នាំ២០១៦ នេះ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុដែលក្នុងនោះមាន៥ការិយាល័យ និងបានបំពេញសកម្មភាពការងារដូចខាងក្រោម៖

**ស្ថានភាពទូទៅ៖**

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ជាសេនាធិការជូនថ្នាក់ដឹកនាំលើកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ ហើយជាអ្នកសម្របសម្រួល និងគាំទ្រ ដល់បណ្តានាយកដ្ឋានបច្ចេកទេស ដើម្បីអនុវត្តផែនការសកម្មភាពឱ្យមានការរីកចម្រើន។ នាយកដ្ឋាន ដែលមាន៥ការិយាល័យនេះ បានបំពេញសកម្មភាពការងារដូចខាងក្រោម៖

**ការងារអនុវត្តសម្រេចបាន៖**

១. បានទទួលលិខិតចូលចំនួន ២៣។

២. បានបញ្ជូនលិខិតចេញទៅបណ្តារាជធានី-ខេត្តចំនួន០៩។

៣. បានបញ្ជូនលិខិតចេញទៅក្រសួងចំនួន០៤។

៤. បានរៀបចំលិខិតបេសកកម្មជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាចំនួន ២៩។

៥. បានបញ្ចប់ការធ្វើបញ្ជីសារពើភ័ណ្ឌតាមបន្ទប់ និងនាយកដ្ឋាននីមួយៗ ។
៦. បានបញ្ចប់ការបើកសម្ភារៈការិយាល័យត្រីមាសទី២ជូនថ្នាក់ដឹកនាំ ទីប្រឹក្សាជំនួយការអគ្គលេខាធិការ អគ្គលេខាធិការរង និងនាយកដ្ឋានទាំង០៤ រួចរាល់។
៧. បានធ្វើលិខិតស្នើសុំថវិកាសម្រាប់ការចំណាយលើការប្រើប្រាស់ក្នុងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
៨. បានបញ្ចប់ការធ្វើបញ្ជីស្វ័យប្រកាស និងប្រវត្តិរូបមន្ត្រីជាប់កិច្ចសន្យាតាមគោលការណ៍ណែនាំរបស់ក្រសួងមុខងារសាធារណៈ ។
៩. បានបញ្ជូនទិន្នន័យមន្ត្រីជាប់កិច្ចសន្យាគ្រប់ចំនួន ៣០រូប ផ្ញើជូនក្រសួងមុខងារសាធារណៈ។
១០. សំណើសុំដំឡើងថ្នាក់ជូនថ្នាក់ដឹកនាំ និងមន្ត្រីរួចរាល់។
១១. រៀបចំបញ្ជីវត្តមានប្រចាំថ្ងៃ និងបូកសរុប។
១២. ប្រមូលរបាយការណ៍ប្រចាំខែរបស់មន្ត្រីជាប់កិច្ចសន្យា។
១៣. ស្នើសុំឥណទានថវិកាជាតិជំពូក៦៤ ប្រាក់បៀវត្សមន្ត្រីជាប់កិច្ចសន្យាប្រចាំខែឧសភា ឆ្នាំ២០១៦ រួចរាល់។
១៤. ស្នើសុំទូទាត់ថវិការជួរទេយ្យបុរេប្រទានតាមកម្មវិធីជំពូក៦១ ប្រាក់បេសកកម្មក្នុងប្រទេសជូនមន្ត្រីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍រួចរាល់។
១៥. បានបញ្ចូលទឹកប្រាក់បេសកកម្ម(មូលប្បទានបត្រ)ទៅធនាគារអេស៊ីលីដា។
១៦. ពិនិត្យតាមដានឥណទានជាប្រចាំ។
១៧. ទំនាក់ទំនងជាមួយក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារជាតិ ក្នុងការបិទបញ្ជីឆ្នាំចាស់ ២០១៥ បន្តការងារឆ្នាំ២០១៦។
១៨. បញ្ចូលអាណត្តិដែលបានរៀបចំទូទាត់រួច ទៅអង្គភាពទាំងបីខាងលើ។
១៩. លើកគោលការណ៍ប្រជុំពេញអង្គលើកទី១ ។

# ៣. ផែនការសកម្មភាព និងទិសដៅសម្រាប់ខែឧសភា ឆ្នាំ២០១៦

## ៣.១. នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ

**ការងារសម្រាប់ខែបន្ទាប់៖**

១. បន្តការពិភាក្សាអំពីការងារNASAនេះដើម្បីត្រៀមសម្រាប់កិច្ចប្រជុំផ្សព្វផ្សាយជាផ្លូវការ ការអង្កេតជាតិស្តីពីការចំណាយក្នុងការប្រយុទ្ធនឹងជំងឺអេដស៍

សម្រាប់ឆ្នាំ២០១៤-២០១៥ នៅថ្ងៃទី ៤-៥ ខែឧសភា ឆ្នាំ២០១៦ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ។

២. បន្តស្រាវជ្រាវឈ្មោះរបស់អ្នកចូលរួមពីស្ថាប័ន និងផ្ញើសារអំពីការអញ្ជើញចូលរួមកិច្ចប្រជុំផ្សព្វផ្សាយជាផ្លូវការ ការអង្កេតជាតិស្ដីពីការចំណាយក្នុងការប្រយុទ្ធនឹងជំងឺអេដស៍សម្រាប់ឆ្នាំ២០១៤-២០១៥ នៅថ្ងៃទី ៤-៥ ខែឧសភា ឆ្នាំ២០១៦ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញជូនទៅក្រសួង និងស្ថាប័នពាក់ព័ន្ធ។

៣. បន្តការងារធ្វើការប្រមូលរបាយការណ៍ វឌ្ឍនភាពឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ ផ្ញើជូនអង្គការសហប្រជាជាតិ (GARPR) ២០១៥។

៤. បន្តធ្វើការកែសម្រួលសៀវភៅផែនការយុទ្ធសាស្ត្រជាតិលើកទី៤ NSP IV។

៥. បន្តធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែមេសា ឆ្នាំ២០១៦ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៦. បន្តធ្វើរបាយការណ៍សកម្មភាពបានអនុវត្តប្រចាំសប្ដាហ៍ទី១ ដល់ ទី៤ នៅក្នុងខែឧសភា ឆ្នាំ២០១៦ របស់នាយកដ្ឋាន PMER ។

៧. ត្រៀមចូលរួមកិច្ចប្រជុំបច្ចេកទេសប្រចាំសប្ដាហ៍ នៅថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០១៦ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៨. បន្តតាមដានលើរឿងលទ្ធផលការងារ SOP និង MCPI ។

៩. បន្តទំនាក់ទំនងជាមួយ PR/NCHADS ទាក់ទងនឹងការងារអនុវត្តគម្រោង។

## ៣.២. នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

**ការងារសម្រាប់ខែបន្ទាប់៖**

១. ប្រជុំគណៈកម្មាធិការថវិកាស្ដីពីការពិនិត្យលើកគម្រោងថវិកាជាតិសម្រាប់ឆ្នាំ២០១៧ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦។

២. រៀបចំចាត់តាំងមន្ត្រីចុះបេសកកម្មខេត្តប៉ៃលិន នៅថ្ងៃទី២៤ ដល់ ទី២៦ ខែមេសា ឆ្នាំ២០១៦។

៣. Follow Up ទិន្នន័យអ្នកផ្ទុកមេរោគអេដស៍ដែលជាប់ជាគ្រួសារក្រីក្រ ដើម្បីទទួលបានប័ណ្ណសមធមិដែលផ្ញើពីអង្គការបណ្ដាញអ្នកផ្ទុក។

៤. រៀបចំរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាគោលនយោបាយ។

## ៣.៣. នាយកដ្ឋាន បង្ការ ថែទាំ និងគាំទ្រ

**ការងារសម្រាប់ខែបន្ទាប់៖**

១. បន្តជួយដល់ក្រសួងពាក់ព័ន្ធ (ជាជំនួយបច្ចេកទេស និងចូលរួមសម្របសម្រួល) ក្នុងការរៀបចំកម្មវិធីស្តីពីកុមារកំព្រា និងកុមារដែលងាយរងគ្រោះដោយសារមេរោគអេដស៍ និងជំងឺអេដស៍។

២. ចុះអភិបាលកិច្ច លើការអនុវត្តន៍ការងារឆ្លើយតបទៅនឹងការកាត់បន្ថយការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍នៅតាមបណ្តាខេត្ត។

៣. ចូលរួមកិច្ចប្រជុំនានា ដើម្បីពង្រឹងកិច្ចសហការជាមួយស្ថាប័នពាក់ពាក់ព័ន្ធក្នុងការឆ្លើយតបទនឹងការកាត់បន្ថយការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍។

៤. បន្តចូលរួមអនុវត្តផែនការមូលនិធិសកល នឹងផែនការថវិកាជាតិ។

៥. ចូលរួមប្រជុំបច្ចេកទេសជាមួយថ្នាក់ដឹកនាំ រៀងរាល់សប្តាហ៍ និងរៀងរាល់ខែ។

៦. តាមដាន និងពិនិត្យរាល់ការអនុវត្តន៍ការងារឆ្លើយតបទៅនឹងការកាត់បន្ថយការរីករាលដាលនៃមេរោគអេដស៍ និង ជំងឺអេដស៍របស់ រាជធានី/ខេត្ត និងស្ថាប័នពាក់ព័ន្ធ។

៧. ចូលរួមរៀបចំកិច្ចប្រជុំលេខាធិការដ្ឋាន បុរសស្រឡាញ់បុរស និងស្រីស្រស់ នឹងរៀបចំកិច្ចប្រជុំ ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ ប្រចាំខែ និងត្រីមាស។

## ៣.៤. នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

**ការងារសម្រាប់ខែបន្ទាប់៖**

១. រៀបចំលិខិតបេសកកម្មជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា។

២. ធ្វើលិខិតស្នើសុំថវិកាសម្រាប់ចំណាយការប្រើប្រាស់ក្នុងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣. ត្រៀមរៀបចំសលាកប័ត្រឃ្លាំង។

៤. បន្តរៀបចំបញ្ជីវត្តមានថ្មីតាមអនុក្រឹត្យ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា។

៥. បន្តផ្ទៀងផ្ទាត់ឯកសារបេសកកម្មដែលបានឡើងទូទាត់រួចហើយ ក្នុងទឹកប្រាក់១០៧លានរៀល។

៦. រៀបចំតារាងបញ្ចូលទឹកប្រាក់បេសកកម្ម (មូលប្បទានប័ត្រ) ទៅធនាគារអេស៊ីលីដា។ល

ថ្ងៃទី27 ខែឧសភា ឆ្នាំ២០១៦

មន្ត្រីទទួលបន្ទុក

លោកវេជ្ជ. កែវ ចំណាន

បានពិនិត្យត្រឹមត្រូវ

ប្រធាននាយកដ្ឋានផែនការ គ្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ

លោកវេជ្ជ. ទេព ណារុធ

បានឃើញ និងឯកភាព

អគ្គលេខាធិការ

ឯកឧត្តមវេជ្ជ. តែង គន្ធី